# ជួបស្គាល់

# ក្រុមសោថឹនបាប់ទីស្ទ

**តាំងពីជាង ១៧០ ឆ្នាំមកហើយ ដែលគ្រីស្ទបរិស័ទសោថឹនបាប់ទីស្ទ បានខិតខំផ្សព្វផ្សាយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ទៅដល់មនុស្សទាំងអស់នៅគ្រប់ទីកន្លែង។** សោថឹនបាប់ទីស្ទកិនវែនហ្សិន (Southern Baptist Convention) បានត្រូវបង្កបង្កើតឡើង ក្នុងគោលដៅផ្សាយដំណឹងល្អ។ គោលធម្មនុញ្ញនៃអង្គការនេះ ចាក់ផ្តោតទៅលើចំណុចមួយគត់៖... គឺមាន *គោលបំណង ចំរាញ់ បូកបញ្ចូល និងតម្រង់ថាមពលទាំងប៉ុន្មានរបស់គ្រីស្ទបរិស័ទ ក្នុងចំណោមគ្រីស្ទបរិស័ទបាប់ទីស្ទ ដើម្បីការផ្សព្វផ្សាយនៃដំណឹងល្អ។*[†]

សោថឹនបាប់ទីស្ទកិនវែនហ្សិន បានរីកធំធាត់ ហើយបានក្លាយទៅជាបណ្តាញប្រទាក់ព្រះវិហារជាងប្រាំម៉ឺន ដែលជាព្រះវិហារដែលធ្វើសហការក្នុងបេសកកម្ម និងបេសកកម្មដែលមានបែបជាព្រះវិហារ ទាំងពួតដៃគ្នា ដើម្បីឲ្យមានឥទ្ធិពលសំរាប់នគរព្រះ។ ទោះបីមានព្រះវិហារសោថឹនបាប់ទីស្ទធំៗ ប្រមាណពីររយ ដែលគេអាចនឹងហៅថាជាមហាព្រះវិហារ (mega-churches) ក្តី ព្រះវិហារសោថឹនបាប់ទីស្ទភាគច្រើនលើសលប់ មានតែត្រឹមយ៉ាងច្រើនពីររយនាក់ប៉ុណ្ណោះដែលចូលថ្វាយបង្គំព្រះជារៀងរាល់សប្តាហ៍។ គ្មានព្រះវិហារសោថឹនបាប់ទីស្ទពីរណា ដែលមានលក្ខណៈដូចគ្នាបេះបិទនោះទេ ប៉ុន្តែ ព្រះវិហារទាំងនេះ មានគុណសម្បត្តិមួយចំនួនប្រហាក់ប្រហែលគ្នា ដែលជាចំណងចងភ្ជាប់ព្រះវិហារសោថឹនបាប់ទីស្ទទាំងនេះ ឲ្យសាមគ្គីគ្នាជាធ្លុងមួយ ទោះបីជាគេមានពណ៌សម្បុរ ជាតិសាសន៍ ឋានៈសេដ្ឋសង្គម ភាសា មាឌ ឬទីតាំងខុសៗគ្នាក្តី។

យើងនឹងពិពណ៌នាជូនទ្រួសៗអំពីទិដ្ឋភាពជាទូទៅ នៃកិច្ចការដែលព្រះជាម្ចាស់កំពុងធ្វើ តាមរយៈគ្រីស្ទបរិស័ទសោថឹនបាប់ទីស្ទ។



ព្រះវិហារសោថឹនបាប់ទីស្ទនីមួយៗ ជាព្រះវិហារស្វ័យ័ត និងប្លែកពីគេ។ មានតែនៅពេលដែលគេនៅជុំគ្នាប៉ុណ្ណោះ ទើបគេអាចនឹងដឹងបានថា មានភាពផ្សេងៗពីគ្នា នៅក្នុងអង្គការសោថឹនបាប់ទីស្ទកិនវែនហ្សិន។

## Southern Baptists គឺជានរណា

**សោថឹនបាប់ទីស្ទមានភាពផ្សេងៗគ្នា ព្រមទាំងមានលក្ខណៈប្លែកៗពីគ្នា នៅតាមទីក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍ជនបទ ដែលព្រះវិហារតាំងនៅ។** ព្រះវិហារសោថឹនបាប់ទីស្ទនីមួយៗ ជាព្រះវិហារស្វ័យ័ត និងប្លែកពីគេ។ មានតែនៅពេលដែលគេនៅជុំគ្នាប៉ុណ្ណោះ ទើបគេអាចនឹងដឹងបានថា មានភាពផ្សេងៗពីគ្នា នៅក្នុងអង្គការសោថឹនបាប់ទីស្ទកិនវែនហ្សិន។ ព្រះវិហារសោថឹនបាប់ទីស្ទមានលាយចំរុះគ្នាគ្រប់បែបយ៉ាងដូចជា...

- *ទំហំ៖* ពីព្រះវិហារតូចបំផុត ទៅធំបំផុត
- *វប្បធម៌៖* ពីវប្បធម៌ភាគខាងជើង ទៅភាគខាងត្បូង ភាគខាងកើត ភាគខាងលិច និងវប្បធម៌តាមតំបន់នីមួយៗ
- *អាយុ៖* ពីកូនក្មេង ទៅមនុស្សចាស់ជរា
- *ភិនភាគព័ន្ធកិច្ច៖* ពីផ្នែកខាងក្នុងជ្រៅនៃទីក្រុង ទៅមុខហាងទំនិញ ជាយក្រុង ក្រុងតូចៗ ជនបទ ខោវប៊ិយ ក្រុមអ្នកជិះម៉ូតូ
- *ជាតិសាសន៍ និងក្រុមកុលសម្ព័ន្ធ៖* ជនជាតិស្បែកស ជនជាតិស្បែកខ្មៅ ជនជាតិស្ប៉ាំនីហ្ស ជនជាតិកូរ៉េ ជនជាតិចិន ជនជាតិដើមអាមេរិក ជនជាតិរុស្ស៊ី និងក្រុមកុលសម្ព័ន្ធដទៃៗទៀត
- *ភាសា៖* គេថ្វាយបង្គំព្រះ ដោយប្រើភាសាជាងមួយរយជារៀងរាល់ថ្ងៃអាទិត្យ នៅតាមព្រះវិហារសោថឹនបាប់ទីស្ទ ដែលមានរាយស្ពុះនៅទូទាំងសហរដ្ឋអាមេរិក
- *របៀបថ្វាយបង្គំព្រះ៖* តាមបែបប្រពៃណី តាមសម័យបច្ចុប្បន្ន និងគ្រប់បែបបទ ដែលនៅចន្លោះរបៀបទាំងពីរនេះ
- *ទស្សនៈទេវវិជ្ជា៖* ធ្វើទាំងអស់ក្នុងក្របខ័ណ្ឌ នៃគោលជំនឿ ដែលមានជាប្រវត្តិសាស្ត្រក្នុងព្រះគម្ពីរបរិសុទ្ធ។



ប៉ុន្តែ ដើម្បីឲ្យស្គាល់សោថឹនបាប់ទីស្ទ គេត្រូវយល់ឱ្យច្បាស់ ថាតួអង្គដែលទ្រង់គង់នៅកណ្តាល ហើយដែលធ្វើការ ក្នុងចំណោមពួកយើង គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះយើង។ សោថឹនបាប់ទីស្ទ ជាក្រុមដែលព្រះគ្រីស្ទបានប្រោសលោះ ឱ្យរួចផុតពី *អំពើបាប*-គឺជាភាពកង្វះ ភាពប្រេះឆាខាងព្រលឹងវិញ្ញាណ ដែលបណ្តាលឲ្យយើងមានចិត្តរឹងទទឹងមិនព្រមដើរតាមផ្លូវព្រះ ហើយក៏ខ្វះមិនដល់សិរីល្អនៃទ្រង់។

គ្រីស្ទបរិស័ទសោថឹនបាប់ទីស្ទ លើកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទឡើងយ៉ាងខ្ពស់ គឺទុកព្រះអង្គជាចំណុចកណ្តាល ដែលបង្រួបបង្រួមអ្វីៗទាំងអស់ គឺអ្វីៗដែលបានសាងសង់ឡើង និងព័ន្ធកិច្ចទាំងឡាយក៏ហូរចេញពីព្រះអង្គ។ យើងពោលថា *បង្កើតសមាជិកព្រះវិហារជាថ្មីឡើង* ( Regenerate Church Membership) ដើម្បីដៅបញ្ជាក់ថាចំណុចផ្តើមសំរាប់អ្វីៗគ្រប់ទាំងអស់ ដែលពាក់ព័ន្ធទៅនឹងព្រះវិហារសោថឹនបាប់ទីស្ទនោះ គឺសេចក្តីជំនឿនៃបុគ្គលម្នាក់ៗលើព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់នៃជីវិតរបស់គេ។

គ្រីស្ទបរិស័ទសោថឹនបាប់ទីស្ទជឿថា មនុស្សរាល់រូបជាមនុស្សបាបតាំងពីកំណើតមក និងក៏ជាជម្រើសរបស់ខ្លួនគេដែរ ដូចមានចែងក្នុងគម្ពីររ៉ូម ៣:២៣ ថា "ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ"។ យើងជឿថាព្រះយេស៊ូវដែលបាន "សុគតជំនួសយើងនៅលើឈើឆ្កាង" បានធ្វើការចាំបាច់សព្វគ្រប់ហើយ ដើម្បីផ្តល់សេចក្តីប្រោសលោះដល់មនុស្សឲ្យរួចពីបាប" និងយើងជឿថា "គ្មានសេចក្តីសង្គ្រោះណាទៀត ក្រៅពីជំនឿនៃបុគ្គលម្នាក់ៗផ្ទាល់ខ្លួន លើព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ឡើយ។

## គ្មានសេចក្តីសង្គ្រោះណាទៀត ក្រៅពីជំនឿនៃបុគ្គលម្នាក់ៗ លើព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ឡើយ។

គ្រាដែលព្រះគម្ពីរ មិនបានបង្រៀនថា ពិធីបុណ្យជ្រមុជទឹកមានអំណាច ដែលផ្តល់សេចក្តីសង្គ្រោះ (អេភេសូ ២:៨ ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ) ហើយដើម្បីរក្សាទម្ងន់នៅក្នុងព្រះគម្ពីរ ដែលឆ្លុះបញ្ចាំងតាមរយៈកេរ្តិ៍ដំណែល និងនាមរបស់យើង ព្រមទាំងក្នុងនាមជា "ប្រជារាស្ត្រនៃព្រះគម្ពីរ" គ្រីស្ទបរិស័ទសោថឹនបាប់ទីស្ទជឿថា អ្នកដែលជឿពិតប្រាកដទាំងអស់ច្បាស់ជានឹងចង់ប្រកាសភ្ជាប់ខ្លួនគេដោយពេញលេញ ជាមួយនឹងព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់គេ តាមរយៈការទទួលធ្វើពិធីបុណ្យជ្រមុជទឹក។

យើងជឿថាពិធីបុណ្យជ្រមុជទឹកអ្នកគ្រីស្ទាន គឺជាការពន្លិចអ្នកជឿចុះទៅក្នុងទឹក ក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ (ម៉ាថាយ ២៨:១៩)។ បុណ្យជ្រមុជទឹក គឺជាអំពើដែលធ្វើទៅតាមការបង្គាប់ ហើយក៏ជានិមិត្តរូបនៃ (1) សេចក្តីជំនឿរបស់អ្នកជឿលើព្រះសង្គ្រោះ ដែលទ្រង់ត្រូវគេឆ្កាង ត្រូវបានកប់ក្នុងផ្នូរ និងរួចហើយបានរស់ពីសុគតឡើងវិញ (2) អ្នកជឿបានស្លាប់ក្នុងអំពើបាប ជីវិតចាស់បានត្រូវកប់ចោល និងបានរស់ពីស្លាប់ឡើងវិញ រួចហើយដើរក្នុងជីវិតថ្មី ក្នុងព្រះគ្រីស្ទយេស៊ូវ និង (3) អ្នកជឿដែលជឿទុកចិត្តថា សេចក្តីស្លាប់ គឺត្រឹមតែខាងសាច់ឈាមប៉ុណ្ណោះ ប៉ុន្តែ ឯខាងព្រលឹងវិញ្ញាណវិញ គេនឹងបានជីវិតអស់កល្បជានិច្ច នៅថ្ងៃចុងក្រោយពេលដែលព្រះអង្គប្រោសអ្នកជឿទាំងអស់ឲ្យរស់ឡើងវិញ។

គឺតាមរយៈដំណឹងល្អ ដោយសារដំណឹងល្អ និងដើម្បីដំណឹងល្អ ដែលសោថឹនបាប់ទីស្ទកិនវែនហ្សិនបានកើតមានឡើង។ ដូច្នេះហើយបានជាអ្វីៗដែលស្តីអំពីនិកាយសោថឹនបាប់ទីស្ទ គឺសុទ្ធតែមានភ្ជាប់ដោយផ្ទាល់ទៅនឹងដំណឹងល្អទាំងអស់។

## ជំនឿរបស់សោថឹនបាប់ទីស្ទ

**គ្រីស្ទបរិស័ទសោថឹនបាប់ទីស្ទជឿថា ព្រះគម្ពីរគឺជាការបើកសំដែងអំពីព្រះ ដល់មនុស្សលោក ឯការសំដែងធំកំពូលបំផុត គឺព្រះរាជសារដំណឹងល្អ អំពីការប្រោសលោះតាមរយៈព្រះយេស៊ូវគ្រីស្ទ។** ដោយហេតុនេះ សោថឹនបាប់ទីស្ទ បានសរុបបញ្ជាក់សេចក្តីសច្ចាជំនឿនៃបទគម្ពីររបស់ពួកគេ តាមរយៈឯកសារមួយដែលហៅថា *ជំនឿ និង សារលិខិតរបស់បាប់ទីស្ទ* (The Baptist Faith and Message) (BF&M)។ គ្រីស្ទបរិស័ទសោថឹនបាប់ទីស្ទ មិនមែនជាពួកអ្នកដែលកាន់គោលការណ៍ជំនឿ ដែលតម្រូវឲ្យព្រះវិហារ និងបុគ្គលឱបក្រសោប យកកំណត់ខ្នាតជំនឿនោះទេ។ ប៉ុន្តែ យើងជាពួកអ្នកដែលទទួលស្គាល់ និងសារភាពអំពើបាបរបស់ខ្លួន។ BF&M ជាសេចក្តីប្រកាសជាឯកច្ឆ័ន្ទ ក្នុងការសារភាពលន់តួបាបថាជា "លទ្ធិសាសនាច្បាស់លាស់ មួយចំនួនដែលគ្រីស្ទបរិស័ទបាប់ទីស្ទជឿ ហើយស្រឡាញ់ ព្រមទាំងបានទទួលយកដោយស្និទ្ធិថា ជាសេចក្តីជំនឿរបស់ពួកគេ"។

អត្ថបទប្រាំប្រការខាងដើមរបស់ BF&M ថ្លែងបញ្ជាក់អំពីប្រវត្តិ និងជំនឿដំណឹងល្អ ដែលជាប់ទាក់ទងនឹងបទគម្ពីរ តួអង្គនិងការងាររបស់ព្រះ ធម្មជាតិរបស់មនុស្សនិងការធ្លាក់ក្នុងអំពើបាបរបស់មនុស្ស ព្រះគុណនៃសេចក្តីសង្គ្រោះ ដែលព្រះអង្គបានផ្តល់ឱ្យ តាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទតែមួយគត់ ហើយនឹងគោលបំណង

របស់ព្រះគុណទ្រង់ - គឺព្រះអង្គជាអ្នកផ្តើម ហើយក៏ជាអ្នកសំរេចបង្ហើយ កិច្ចការនៃសេចក្តីសង្គ្រោះ។

ប្រការប្រាំមួយបន្ទាប់ បញ្ជាក់អំពីប្រវត្តិសាស្ត្របាប់ទីស្ទ គោលជំហរបាប់ទីស្ទ យោងទៅតាមព្រះគម្ពីរចំពោះព្រះវិហារ ពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ ទិវានៃព្រះអម្ចាស់ នគរព្រះ គោលលទ្ធិនៃកាលវេលាចុងក្រោយបំផុត ការផ្សព្វផ្សាយដំណឹងល្អ និងគ្រីស្ទបេសកកម្ម។

ប្រការប្រាំពីរចុងក្រោយ គឺជាសេចក្តីសង្ខេប អំពីការប្តេជ្ញា មួយចំនួនរបស់គ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទ ចំពោះកិច្ចការដែលជាប់ទាក់ទងទៅនឹង ចំណេះចេះដឹងថ្នាក់ជាន់ខ្ពស់ នៃគ្រីស្ទបរិស័ទ ភារៈកិច្ចទទួលរ៉ាប់រងទ្រព្យសម្បត្តិ សហការក្នុងព័ន្ធកិច្ចរួម គ្រីស្ទបរិស័ទ និង សណ្តាប់ធ្នាប់ក្នុងសង្គម សន្តិភាព និង សង្គ្រាម សេរីភាពខាងសាសនា ហើយ និងគ្រួសារ។

អត្ថបទទាំងស្រុងនៃ *ជំនឿ និងសារលិខិតរបស់បាប់ទីស្ទ* គឺមាននៅ SBC.net/bfm2000/bfm2000.asp។



# គ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទធ្វើអ្វីខ្លះ

គ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទប្រកាសដំណឹងល្អ តាមរយៈការផ្សាយដំណឹងល្អ និងតាមរយៈការបង្កបង្កើតព្រះវិហារ។

ចំណុចសំខាន់ នៃបេសកកម្មរបស់ពួកយើង គឺជាភាពបន្ទាន់ ដែលជំរុញឲ្យយើងប្រកាសដំណឹងល្អ ទៅដល់មនុស្សគ្រប់ៗគ្នា។ BF&M សរុបសេចក្តីនៃព្រះគម្ពីរថា៖

> «គឺជាករណីយកិច្ច និង ជាឯកសិទ្ធិ របស់អ្នកដើរតាមព្រះគ្រីស្ទ និង របស់គ្រប់ទាំងព្រះវិហារនៃព្រះយេស៊ូវគ្រីស្ទ ក្នុងការខំប្រឹងបង្កបង្កើតសិស្ស នៅក្នុងគ្រប់ជាតិសាសន៍ទាំងអស់» ការកកើតជា ថ្មីឡើងវិញ នៃផ្នែកព្រលឹងវិញ្ញាណរបស់មនុស្ស ដោយព្រះវិញ្ញាណបរិសុទ្ធ បានន័យថា ជាការចាប់កំណើតនៃសេចក្តីស្រឡាញ់ដល់អ្នកជិតខាង។ ដូច្នេះហើយ ការខំប្រឹងប្រែងនៃបេសកជនក្នុងគ្រប់ផ្នែកទាំងអស់ ត្រូវពឹងផ្អែកទៅលើការចាំបាច់ ផ្នែកព្រលឹងវិញ្ញាណ នៃជីវិតថ្មីដែលកកើតឡើង ហើយដែលព្រះយេស៊ូវគ្រីស្ទបានបង្គាប់បញ្ជាម្តងហើយម្តងទៀត យ៉ាងច្បាស់ក្នុងសេចក្តីបង្រៀនរបស់ព្រះអង្គ។ ព្រះអម្ចាស់យេស៊ូវ បានបញ្ជាឲ្យយើងផ្សាយដំណឹងល្អទៅគ្រប់ជាតិសាសន៍។ គឺជាករណីយកិច្ចរបស់បុត្រាបុត្រីរបស់ព្រះគ្រប់រូប ក្នុងការខំប្រឹងប្រែងជានិច្ច ដើម្បីស្វែងរកព្រលឹងដែលបាត់បង់ មកថ្វាយព្រះអង្គ តាមរយៈការធ្វើទីបន្ទាល់ដោយផ្ទាល់មាត់ ដោយមានការរស់នៅ ជាគ្រីស្ទបរិស័ទ ជាសាក្សី និងតាមរបៀបផ្សេងៗទៀត ដែលស៊ីគ្នាជាមួយនឹងដំណឹងល្អរបស់ព្រះគ្រីស្ទ។

## ការផ្សាយដំណឹងល្អ

ដោយការប្តេជ្ញាចិត្តនេះ ព្រះវិហារសោថឺនបាប់ទីស្ទនីមួយៗ តែងតែធ្វើរបាយការណ៍ អំពីចំនួនមនុស្សដែលទទួលធ្វើពិធីបុណ្យជ្រមុជទឹក ជារៀងរាល់ឆ្នាំ តាមរយៈក្រដាសបំពេញរបាយការណ៍ដោយស្ម័គ្រចិត្តមួយ ដែលហៅថា *The Annual Church Profiles*។

**ចំណុចសំខាន់ នៃបេសកកម្មរបស់ពួកយើងនោះ គឺភាពបន្ទាន់ ដែលជំរុញឲ្យយើងប្រកាសដំណឹងល្អ ទៅដល់មនុស្សគ្រប់ៗគ្នា**

---

នៅក្នុងកំឡុងពេល១៥ឆ្នាំដំបូងនៃសតវត្សទី២១ សហការព្រះវិហារសោថឺនបាប់ទីស្ទ បានធ្វើរបាយការណ៍ថា មានមនុស្សចំនួនជាង ៤ លាននាក់ នៅក្នុងសហរដ្ឋអាមេរិក បានទទួលពិធីបុណ្យជ្រមុជទឹក។

**គ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទបានធ្វើការប្តេជ្ញាចិត្តបង្កបង្កើតព្រះវិហារថ្មីៗបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជននៅក្នុងប្រទេសយើង និងពិភពលោកទាំងមូល។**

តាមស្ថិតិនេះ ព្រះវិហារនីមួយៗ មានមនុស្សជាមធ្យមជាងមួយរយនាក់បានទទួលបុណ្យជ្រមុជទឹកក្នុងរយៈកាលនេះ។ គឺជាការដែលយើងគួរតែអបអរទរណាស់ កាលដែលយើងឃើញមនុស្សម្នាក់ៗបានទទួលជឿ ហើយប្រកាសខ្លួន ថាជាកូនរបស់ព្រះយេស៊ូវគ្រីស្ទ ដោយទទួលពិធីបុណ្យជ្រមុជទឹក បើប្រៀបធៀបនឹងសភាពការដ៏ខ្មៅងងឹតនៃពិភពលោក ប៉ុន្តែនៅមានកិច្ចការច្រើនណាស់ ដែលយើងត្រូវតែខំប្រឹងធ្វើតទៅទៀត ដើម្បីជំរុញព្រះនាមព្រះគ្រីស្ទឲ្យទៅមុខ តាមរយៈការផ្សាយដំណឹងល្អ របស់ព្រះគ្រីស្ទយេស៊ូវនៃយើង។

## ការបង្កបង្កើតពួកជំនុំថ្មី

លើសពីនេះទៅទៀត គណៈសោថឺនបាប់ទីស្ទ បានប្តេជ្ញាចិត្តថា នឹងបង្កបង្កើតព្រះវិហារថ្មីៗបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជននៃប្រទេសយើង និងពិភពលោកទាំងមូល។ "គណៈបេសកកម្មអាមេរិកខាងជើង នៃសោថឺនបាប់ទីស្ទកិនវែនហ្សិន" The Southern Baptists Convention's North American Mission Board ( NAMB ) បានកំណត់គោលដៅថា ចង់ឲ្យបានព្រះវិហារថ្មីៗចំនួន ៥ ពាន់ ក្រុមជំនុំ ( ព្រះវិហារ បូកនិងព្រះវិហារបែបបេសកកម្ម ) នៅក្នុងសហរដ្ឋអាមេរិក និងកាណាដា នា ឆ្នាំ ២០២២ ខាងមុខនេះ។ ចំនួននេះបានន័យថា ព្រះវិហារបាទីស្ទនឹងកើនឡើង ១០ភាគរយ ដោយសារសហការរួមចំណែក វាយលុកចូលទៅក្នុងពិភពបាត់បង់ នៅទ្វីបអាមេរិកខាងជើង។ មិនតែប៉ុណ្ណោះ សោថឺនបាប់ទីស្ទកិនវែនហ្សិន ផ្តល់ការផ្គត់ផ្គង់ដោយពេញទំហឹង ដល់គ្រីស្ទបេសកជនផ្សាយដំណឹងល្អនៅក្រៅប្រទេស និងគ្រីស្ទបេសកជន ដែលនាំមុខបង្កបង្កើតព្រះវិហារថ្មីផង។

The Gospel គឺប្រាកដជាដំណឹងល្អពិត ឯគ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទក៏មានចិត្តរំភើបរំជួលក្នុងការប្តេជ្ញាចិត្ត ដើម្បីចែកចាយដំណឹងល្អ រហូតដល់ថ្ងៃដែលព្រះអម្ចាស់នឹងយាងត្រឡប់មកវិញ។

## គ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទ បង្ហាញឲ្យឃើញដំណឹងល្អ តាមរយៈអំពើមេត្តាធម៌

គ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទ យកឧទាហរណ៍ តាមព្រះយេស៊ូវ អំពីសេចក្តីមេត្តាករុណា និងបទបញ្ញារបស់ព្រះអង្គឲ្យស្រឡាញ់ និងថែរក្សាដល់អ្នកក្រខ្វះខាត ( យ៉ូហាន ៣:១៦, លូកា ១០:២៥-៣៧, ម៉ាថាយ ២៥:៣១-៤៦ )។

> "BF&M សង្ខេបអត្ថន័យ នៃបទគម្ពីរថា៖ មធ្យោបាយ និងវិធីទាំងឡាយដែលគេប្រើសម្រាប់ធ្វើឲ្យមានការប្រសើរឡើង នៅក្នុងសង្គម និងការធ្វើឲ្យមានភាពសុចរិតត្រឹមត្រូវឡើង រវាងមនុស្សនិងមនុស្ស អាចនឹងជាជំនួយយ៉ាងពិតប្រាកដ និងជាអចិន្ត្រៃយ៍ កាលណាកិច្ចការទាំងនោះបានចាក់ឫស នៅក្នុងការកើតជាថ្មីឡើង នៃបុគ្គល ដោយព្រះគុណ ដែលផ្តល់សេចក្តីសង្គ្រោះ ក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទប៉ុណ្ណោះ.... យើងគួរតែថែរក្សាកុមារកំព្រាជួយឧបត្ថម្ភជនក្រីក្រ ការពារអ្នកដែលត្រូវគេរំលោភ ជួយមនុស្សចាស់ជរា ជួយឧបត្ថម្ភអ្នកដែលគ្មានទីពឹងពំនាក់ និងថែរក្សាអ្នកមានជម្ងឺឈឺថ្កាត់"។

## ព័ន្ធកិច្ចនៅក្នុងស្រុកភូមិ

ព្រះវិហារសោថឺនបាប់ទីស្ទនៅទូទាំងប្រទេស បង្ហាញឲ្យឃើញនូវសេចក្តីមេត្តាអាសូររបស់ព្រះជាម្ចាស់ ដល់ជនខ្វះខាត នៅក្នុងសហគមន៍ គឺជាខ្នាតបន្ទាត់ជាបន្តៗ នៃព័ន្ធកិច្ចរបស់គេ៖

- ព្រះវិហារមួយនៅទីជនបទ ក្នុងរដ្ឋ Arkansas បានផានាផ្តល់រោងដាក់ម្ហូប និងបន្ទប់ផ្ទុកខោអាវ នៅក្នុងទីក្រុងតូចមួយ
- ព្រះវិហារមួយនៅទីក្រុង New Orleans បានជួយគាំទ្រយ៉ាងសកម្ម ដល់មជ្ឈមណ្ឌលមួយ ដែលរកដំណោះស្រាយវិបត្តិស្ត្រីមានផ្ទៃពោះ និងជួយក្មេងស្រីដែលមានផ្ទៃពោះ
- ព្រះវិហារមួយនៅ Lower Manhattan ផានាចែកម្ហូបអាហារដល់ជនក្រីក្រ រាល់ល្ងាចថ្ងៃពុធ និងចែកអាហារថ្ងៃត្រង់ នៅសួនច្បារមួយ រាល់ថ្ងៃសៅរ៍។
- ព្រះវិហារមួយនៅក្រុង San Francisco ជួយជនក្រីក្រ ដែលគ្មានទីជម្រក
- ព្រះវិហារមួយនៅទីក្រុង Atlanta ស្វែងរករំដោះកុមារី និងក្មេងស្រី ដែលទទួលរងគ្រោះ ជាប់ជាទាសករខាងផ្លូវភេទ។

ព្រះវិហារសោថឺនបាប់ទីស្ទទូទាំងប្រទេស បានបង្ហាញសេចក្តីស្រឡាញ់ និងមេត្តាករុណារបស់ព្រះ យ៉ាងសកម្ម នៅក្នុងសហគមន៍របស់គេ មិនថាឡើយតាមរយៈសេវាផ្តល់ការថែសុខភាព ដោយឥតគិតថ្លៃ តាមរយៈថ្នាក់បង្រៀនភាសាអង់គ្លេសជាភាសាទីពីរ ឬតាមរយៈការជួយបង់ថ្លៃជួលផ្ទះថ្លៃភ្លើង ដល់គ្រួសារដែលមានសេចក្តីត្រូវការក្នុងស្រុកភូមិ។ តាមការពិត ទំហំនៃព័ន្ធកិច្ច ដែលបង្ហាញសេចក្តីមេត្តាករុណា របស់គ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទ មានភាពទូលំទូលាយ ដូចជាភាពធំធេង នៃសហរដ្ឋអាមេរិកដូច្នោះដែរ។ នេះគឺជាកិច្ចការធម្មតា សំរាប់គ្រីស្ទបរិស័ទសោថឺនបាប់ទីស្ទ នៅគ្រប់ទិសទីគ្រប់ដំបន់ នៅក្នុងប្រជាជាតិនេះ។

## ព័ន្ធកិច្ចសហការ

នៅលើឆាកជាតិ សោថឺនបាប់ទីស្ទបានពួតដៃគ្នា ដើម្បីពង្រីកទង្វើមេត្តាករុណារបស់ព្រះគ្រីស្ទ តាមរយៈមធ្យោបាយច្រើនយ៉ាង។ ព័ន្ធកិច្ចពីរយ៉ាងខាងក្រោម នឹងផ្តល់ឧទាហរណ៍នៃសហការនេះ។

### "អង្គការសោថឺនបាប់ទីស្ទ ជួយសំរាល គ្រោះមហន្តរាយ"

Southern Baptists Disaster Relief ( SBDR ) បញ្ជូនគ្នីគ្នាទៅជួយនៅពេលមានអគ្គីភ័យ ព្យុះទឹកកក ព្យុះកំបុតត្បូង ខ្យល់ព្យុះខ្យល់ព្យុះសង្ឃរា ហើយនិងទឹកជំនន់នៅជុំវិញសហរដ្ឋអាមេរិក។ SBDR ជាអង្គការផ្តល់ជំនួយមួយ ក្នុងចំណោមអង្គការបី ដែលធំជាងគេ នៅក្នុងសហរដ្ឋអាមេរិក និងមានរាប់ទាំងកិច្ចការជួយ



សំអាត និងសាងសង់ឡើងវិញក្រោយពីមានទឹកជំនន់។ ក្រុមស្ម័គ្រចិត្តសោថឹនបាប់ទីស្ទជាអ្នករៀបចំអាហារ ដែលចែកចេញទៅ ដោយអង្គការកាកបាតក្រហមអាមេរិកាំង និងផ្តល់សេវានៅពេលមានគ្រោះមហន្តរាយផ្សេងៗទៀត។ សោថឹនបាប់ទីស្ទ មានកងចល័តជាង ១,៥៥០ កន្លែង ដែលផ្តល់ជំនួយបន្ទាន់ នៅពេលមានគ្រោះមហន្តរាយ នៅតាមស្រុកភូមិ រដ្ឋ និងសហរដ្ឋ ដោយមានអ្នកធ្វើការស្ម័គ្រចិត្ត ដែលសុទ្ធតែបានទទួលការហាត់ហ្វឹកហ្វឺន ជាងដប់ម៉ឺននាក់ នៅរាយទូទាំងប្រទេស។



**"អង្គការសោថឹនបាប់ទីស្ទ ផ្តល់ជំនួយទុរភិក្សសាកល "** Southern Baptists Global Hunger Relief (GHR) ទទួលវិភាគទានពិសេសពីបុគ្គល ក្នុងក្រុមជំនុំនានា បន្តៗពេញឆ្នាំ សំរាប់ចំណាយក្នុងអង្គការនេះ។ វិភាគទានទាំងនេះ ត្រូវបែងចែកចេញជាពីរចំណែកគឺ ៨០ ភាគរយសំរាប់ជួយជនទុរភិក្សនៅក្រៅប្រទេស និង២០ភាគរយទៀតសំរាប់ជនទុរភិក្សក្នុងប្រទេស។ យើងបានប្រមូលវិភាគទាន និងចំណាយអស់ទឹកប្រាក់ចំនួន ៥៦ លានដុល្លារ នៅក្នុងទសវត្សន៍កន្លងទៅនេះ។ ដោយហេតុថា បេសកកម្មនិងព័ន្ធកិច្ចរួម នៃពួកសោថឹនបាប់ទីស្ទដែលមានឈ្មោះថា ប្រូក្រាមសហការនេះ ផ្តល់ប្រាក់ចំណាយខាងការចាត់ការ ទៅខិនវែនហ្សិនមួយរយភាគរយនៃទឹកប្រាក់ដុល្លារដែល GHR បានទទួល ត្រូវប្រើទាំងអស់សំរាប់ចំណាយក្នុងសេចក្តីត្រូវការវិបត្តិទុរភិក្ស។ បន្ថែមពីលើម្ហូបអាហារ និងការជួយសំរាលការអត់ឃ្លាន តាមរយៈគំរោងការណ៍រាប់ពាន់ក្នុងប្រទេសរាប់រយ មនុស្សមួយចំនួន ក្នុងចំណោមអ្នកក្រីក្រអត់ឃ្លាននេះ បានឮអំពីព្រះយេស៊ូវ គឺនំបុ័ងជីវិត សំរាប់ព្រលឹងដ៏ក្រខ្សត់របស់គេ។

## របៀប និង ទីកន្លែង ដែលសោថឹនបាប់ទីស្ទរុញដំណឹងល្អទៅមុខ

**ព្រះវិហារសោថឹនបាប់ទីស្ទ ទូទាំងប្រទេស ប្រកាសដំណឹងល្អទៅដល់អ្នកជិតខាង ក្នុងស្រុកភូមិ ដែលជាសហគមន៍របស់ខ្លួន។ ប៉ុន្តែកុំឈប់នៅតែត្រឹមនេះ។** កម្លាំងនៃសោថឹនបាប់ទីស្ទ គឺស្ថិតនៅលើសហការស្ម័គ្រចិត្ត ក្នុងការធ្វើការរួមសាមគ្គីគ្នា ដើម្បីរុញច្រានទស្សនៈវិស័យសាកល ឲ្យទៅមុខ ដោយស្វាហាប់ ព្រមជាមួយនឹងការរក្សាព័ន្ធកិច្ច នៅក្នុងមូលដ្ឋានផ្ទះសម្បែង ឲ្យមានផលផ្លែ។

សហការរួម ពុំមែនជាគំនិតថ្មីឡើយ។ សាវ័កប៉ូល បានថ្លែងសរសើរក្រុមព្រះវិហារក្នុងព្រះគម្ពីរសញ្ញាថ្មី ដោយសារពួកគេបានដាក់ធនធានរបស់ពួកគេបញ្ចូលជាមួយគ្នា ក្នុងគោលដៅពង្រីកពង្រឹងនគរព្រះ (កូរិនថូសទី១ ១៦:១, កូរិនថូសទី២ ៨:១-២,១៦-២៤, ១១:៨)។ ឯកសារ ជំនឿ និង សារលិខិតរបស់បាប់ទីស្ទ (BF&M) សង្ខេបលំនាំសហការនេះ ក្នុងព្រះគម្ពីរ ដូចខាងក្រោម៖

> យោងទៅតាមពេលវេលាដែលឱកាសហុចឲ្យ គ្រីស្ទជនត្រូវរៀបចំជាសមាគម និងជាខិនវែនហ្សិន ដើម្បីធានាឲ្យសហការមានភាពប្រសើរបំផុត ដើម្បីបំពេញកម្មវត្ថុនៃនគរព្រះ។ អង្គការរបៀបនេះ ពុំមានសិទ្ធិអំណាចគ្រប់គ្រងលើគ្នា ឬលើព្រះវិហារទេ គឺគ្រាន់តែជាអង្គការស្ម័គ្រចិត្ត និងជាទីប្រឹក្សា ក្នុងគោលបំណងចម្រាញ់ បូកបញ្ចូល និងដម្រង់ឋាមពលពួកយើង ឲ្យមានប្រសិទ្ធិភាពខ្លាំងក្លាបំផុតប៉ុណ្ណោះ។ សមាជិកនៃក្រុមជំនុំសញ្ញាថ្មី គួរតែសហការគ្នា ក្នុងដំណើរឈានទៅមុខនៃពន្ធកិច្ចគ្រីស្ទបេសកកម្ម ការបណ្តុះវិជ្ជា ទង្វើមេត្តាករុណា ដើម្បីនឹងពង្រីកពង្រឹងមហានគរនៃព្រះគ្រីស្ទ។

### ប្រូក្រាមសហការ (Cooperative Program) - ប្រមូលដង្វាយសំរាប់ជំរុញដំណឹងល្អឲ្យទៅមុខ

កិច្ចសហការគ្នា ជាជំនួយជួយបញ្ជោះបេសកកម្ម និងព័ន្ធកិច្ចរបស់សោថឹនបាប់ទីស្ទ ឲ្យពុះពោរឡើង។ នៅក្នុងវង្វង់ផ្ទះសម្បែង ព្រះវិហារសោថឹនបាប់ទីស្ទបោះជំហានទៅមុខ ក្នុងការផ្សាយដំណឹងល្អ ដោយធ្វើសហការគ្នា ក្នុងសមាគមព្រះវិហារសោថឹនបាប់ទីស្ទ ដែល

នៅដំបន់របស់ខ្លួន។ លើសពីនេះទៅ សោថឺនបាប់ទីស្ទ ផ្សាយនគរព្រះឯនាយ តាមរយៈការខំខ្នះខ្នែងក្នុងបេសកកម្ម ក្នុងសេចក្ដីអធិស្ឋាន ដែលផ្តោតទៅលើកិច្ចណាមួយចំៗ និងការលើកដង្វាយសំរាប់ជួយប្រូក្រាមសហការ ដែលជាកម្មវិធីរួម សំរាប់ជួយកិច្ចការប្រមូលប្រាក់ ក្នុងរង្វង់អង្គការកិនវែនហ្សិន។

ព្រះវិហារសោថឺនបាប់ទីស្ទ គាំទ្រ ប្រូក្រាមសហការ ដោយបញ្ជូនប្រាក់ដង្វាយ តាមរយៈបណ្ដាញ នៃកិនវែនហ្សិនបាប់ទីស្ទ ក្នុងរដ្ឋ និងក្នុងដំបន់។ អង្គការបាប់ទីស្ទកិនវែនហ្សិនរដ្ឋ ប្រើប្រាក់មួយចំណែកដែលបានទទួល សំរាប់រុញគោលដៅ ព័ន្ធកិច្ចនិងបេសកកម្ម ដែលបានកំណត់ទុក ដោយព្រះវិហារនៅក្នុងរដ្ឋនោះ។ រួចហើយអង្គការបាប់ទីស្ទកិនវែនហ្សិន នៅក្នុងរដ្ឋនិមួយៗ ក៏បញ្ជូនទឹកប្រាក់ ជាចំនួនភាគរយ ទៅអង្គការសោថឺនបាប់ទីស្ទកិនវែនហ្សិន។ គឺទឹកប្រាក់ចុងក្រោយនេះហើយ ដែលប្រើសំរាប់ផ្ដល់ហិរញ្ញវត្ថុ ដល់អ្នកបង្កបង្កើតក្រុមជំនុំថ្មី និងបេសកជនរាប់ពាន់នាក់ នៅអាមេរិកខាងជើង និងនៅជុំវិញពិភពលោក សំរាប់ការសិក្សាទេវវិទ្យា នៅតាមសេមីណារីសោថឺនបាប់ទីស្ទទាំងប្រាំមួយ សំរាប់និស្សិតពេញម៉ោង និងមិនពេញម៉ោង ជាង ១៨,000 នាក់ និងអង្គការគាំទ្រសីលធម៌ និងលើកដំកើងសេរីភាពសាសនា។ ទឹកប្រាក់ប្រូក្រាមសហការ ដែលបញ្ជូនមកពីរដ្ឋ ក៏ផ្ដល់មូលធនសំរាប់ប្រើ ក្នុងថវិកាប្រតិបត្តិការ នៃសោថឺនបាប់ទីស្ទកិនវែនដែរ។

ជាការពិតណាស់ ថាដើម្បីផ្សាយសារដំណឹងល្អឲ្យរាលដាល ទៅក្នុងស្រុកភូមិ និងទៅប្រជាជាតិ គេត្រូវការឱ្យមានការរៀបចំចាត់ចែង និងរចនាសម្ព័ន្ធ ដើម្បីជួយសម្រួលដល់គោលដៅ។ ដើម្បីទទួលដំណឹងបន្ថែមអំពីរចនាសម្ព័ន្ធ នៃអង្គការសោថឺនបាប់ទីស្ទកិនវែនហ្សិន សូមអានការបោះពុម្ពផ្សាយក្នុងផ្នែកនិមួយៗ នៃបេសកកម្ម និងព័ន្ធកិច្ច ព្រមជាមួយនឹង *The Southern Baptist Convention: A closer look.*



កិនវែនហ្សិន (មហាសន្និបាត)-ពួតដៃគ្នាធ្វើការ ដើម្បីដំណឹងល្អ

សោថឺនបាប់ទីស្ទកិនវែនហ្សិន បានកកើតឡើងដើម្បីផ្ដល់នូវការរៀបចំទូទៅមួយ សម្រាប់គ្រីស្ទបរិស័ទបាទីស្ទ នៅសហរដ្ឋអាមេរិកទាំងមូល ព្រមទាំងដែនដីពាក់ព័ន្ធ ក្នុងបំណងពង្រីកគ្រីស្ទបេសកកម្ម នៅក្នុងស្រុកផង និងនៅក្រៅប្រទេសផង ព្រមទាំងពង្រីកកម្មវត្ថុឯទៀតៗ ដូចជាការសិក្សា អំពីសាសនាព្រះគ្រីស្ទ អង្គការជួយខាងផ្នែកមេត្តាករុណា និងសេវាសង្គមកិច្ច ដែលសមរម្យ និងដែលគួរធ្វើ សំរាប់ឲ្យនគរព្រះ បានរីកចំរើនទៅមុខ។

អ្នកតំណាង ដែលហៅថាជា *អ្នកនាំសារ* ចេញពីព្រះវិហារសោថឺនបាប់ទីស្ទ ដែលមានចូលសហការ ជួបជុំគ្នាជារៀងរាល់ឆ្នាំ ដើម្បីអនុម័តថវិកាដែលបែងចែកជាឡែកៗ ក្នុងប្រូក្រាមសហការ ជ្រើសរើសក្រុមប្រឹក្សាភិបាល ដើម្បីត្រួតពិនិត្យមើល អង្គភាពព័ន្ធកិច្ច ក្នុងកិនវែនហ្សិន ទទួលរបាយការណ៍ពីអង្គភាពអង្គការសោថឺនបាប់ទីស្ទកិនវែនហ្សិន ព្រមទាំងសំរេចការផ្សេងទៀត ក្នុងកិនវែនហ្សិន។ អ្នកនាំសារទាំងនេះ សុទ្ធតែត្រូវបានបញ្ជូនមកពីបណ្ដាព្រះវិហារ ដែលបានប្រកាសថា គេមានចំណែកជាមួយសោថឺនបាប់ទីស្ទកិនវែនហ្សិន ព្រមទាំងបានធ្វើវិភាគទានគាំទ្របេសកជន ការអប់រំ ការគាំទ្រផ្នែកសីលធម៌ និងការងារផ្នែកមេត្តាករុណា នៃមហាសន្និបាត។

សោថឺនបាប់ទីស្ទ ពួតដៃគ្នាផ្សាយដំណឹងល្អ ឲ្យរាលដាលពាសពេញទូទាំងប្រទេស នឹងនៅជុំវិញពិភពលោក។ កិច្ចការបណ្ដាញតាមរយៈសមាគមនៅតាមភូមិភាគផ្សេងៗជាងមួយពាន់កន្លែង តាមរយៈប្រិយសម្ព័ន្ធជាតិសាសន៍ជាច្រើន ព្រមទាំងតាមរយៈអង្គការកិនវែនហ្សិន ក្នុងរដ្ឋ និងក្នុងដំបន់ចំនួនទាំងអស់ ៤២ កន្លែង សោថឺនបាប់ទីស្ទបានស្ម័គ្រចិត្តរួមគ្នាចូលប្រឡូក តាមលំនាំក្នុងខគម្ពីរ កិច្ចការ ១:៨ ក្នុងការ

ផ្សាយដំណឹងល្អឲ្យរាលដាល ក្នុងសហគមន៍ភូមិផងរបងជាមួយ ទៅដល់គ្រប់រដ្ឋ ទៅទូទាំងប្រទេស ព្រមទាំងនៅជុំវិញពិភពលោក។

### អង្គភាពព័ន្ធកិច្ចសោថឹនបាប់ទីស្ទ-ការផ្តល់ជំនួយដល់ព្រះវិហារ ក្នុងការផ្សព្វផ្សាយដំណឹងល្អ

អង្គការកិនវែនហ្សិន ចាត់ចែង និងធ្វើកិច្ចការរបស់ខ្លួន តាមរយៈអង្គភាពព័ន្ធកិច្ច ចំនួន ១១ ដែលក្នុងនោះមាន - គណៈបេសកកម្ម ២ សេមីណារី ចំនួន ៦ គណៈកម្មការសីលធម៌ និង សេរីភាពសាសនា ព័ន្ធកិច្ចបោះពុម្ពផ្សាយ និងសេវាធនធានហិរញ្ញវត្ថុ - និងគណៈកម្មាធិការប្រតិបត្តិ។ អង្គការនេះ ក៏ធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនឹងអង្គការជំនួយមួយ ដែលមានឈ្មោះថា សហព័ន្ធក្រុមស្ត្រីបំរើបេសកជន (Women's Missionary Union - WMU)។ ខណៈដែលព័ន្ធកិច្ចទាំងនេះមួយចំនួន អាចនឹងដំណើរការបាន ដោយប្រើធនធានផ្ទាល់ខ្លួន ព័ន្ធកិច្ចភាគច្រើន បានទទួលការឧបត្ថម្ភគាំទ្រ ពីព្រះវិហារដែលផ្តល់ធនធានហិរញ្ញវត្ថុ តាមរយៈប្រូក្រាមសហការ។ ក្នុងវិភាគទានទាំងអស់ ដែលសោថឹនបាប់ទីស្ទកិនវែនហ្សិន បានទទួល ៧៣,២ ភាគរយ ត្រូវប្រើសំរាប់បេសកកម្ម និង កិច្ចការបង្កើតព្រះវិហារថ្មី និង ២២ ភាគរយទៀត ផ្តល់សម្ភារៈបង្ហាត់ហ្វឹកហ្វឺន តាមរយៈសេមីននារីនានា។ អង្គភាពព័ន្ធកិច្ចនិមួយៗ កើតមានឡើង ក្នុងបំណងផ្តល់ជំនួយ ដល់ព្រះវិហារ ដើម្បីបំពេញគោលដៅផ្សាយដំណឹងល្អ ឲ្យរាលដាលចេញទៅ។

- បេសកកម្ម ការផ្សាយដំណឹងល្អ និងការបង្កើតព្រះវិហារថ្មី គឺសំរបសំរួលដោយ **គណៈបេសកកម្មអន្តរជាតិ** (International Mission Board) និង**គណៈបេសកកម្មអាមេរិកខាងជើង** (North American Mission Board)។
- ការរៀបចំព័ន្ធកិច្ច និងការបណ្តុះបណ្តាលវិជ្ជាបន្ថែម គឺផ្តល់ចេញទៅ ដោយសេមីណារីទេវវិជ្ជាបាប់ទីស្ទ Gateway, New Orleans, Midwestern, Southeastern, Southern និង South-western។
- ព័ន្ធកិច្ច ខ្នាតនៃគ្រីស្ទសីលធម៌ និងសេរីភាពសាសនា គឺចាត់ទៅ **គណៈកម្មការ ខ្នាតគ្រីស្ទសីលធម៌ និងសេរីភាពសាសនា** (Ethics and Religious Liberty Commission)។
- ព័ន្ធកិច្ចបំប៉នព្រះវិហារ និងការបោះពុម្ពនិពន្ធ គឺចាត់ទៅ LifeWay Christian Resources។ ក្រុមនេះពុំមានទទួលប្រាក់ជំនួយអ្វីពីប្រូក្រាមសហការទេ។
- GuideStone Financial Resources ក៏គ្មានទទួលប្រាក់ជំនួយអ្វីពីប្រូក្រាមសហការដែរ។ អង្គការនេះ កាន់កាប់ប្រាក់និវត្តន៍និងសេវាធានារ៉ាប់រង ព្រមទាំងគ្រប់គ្រង Mission:Dignity ដែលជាព័ន្ធកិច្ចជំនួយមួយ សំរាប់បុគ្គលិកដែលចូលនិវត្ត និងក្រុមគ្រួសាររបស់គេ។
- **គណៈកម្មការប្រតិបត្តិ នៃសោថឹនបាប់ទីស្ទកិនវែនហ្សិន** (SBC Executive Committee) ទទួលបន្ទុកដឹកនាំកិច្ចការ ក្នុងខិនវែនហ្សិន នៅចន្លោះពេលប្រជុំមហាសន្និបាតប្រចាំឆ្នាំ ពីមួយទៅមួយ ក្នុងគ្រប់ផ្នែកទាំងអស់ លើកលែងតែកិច្ចការណាដែលបានចាត់ទៅឲ្យព័ន្ធកិច្ចណាមួយទទួលខុសត្រូវរួចហើយ។
- **សហព័ន្ធក្រុមស្ត្រីបំរើបេសកជន** (Women's Missionary Union-WMU) គឺជាព័ន្ធកិច្ចជំនួយ តែមួយគត់ របស់សោថឹនបាប់ទីស្ទកិនវែនហ្សិន។ WMU ធ្វើការយ៉ាងជិតស្និទ្ធជាមួយ គណៈបេសកកម្មអន្តរជាតិ (International Mission Board) និងគណៈបេសកកម្មអាមេរិកខាងជើង (North American Mission Board)។ WMU លើកទឹកចិត្តដល់ព្រះវិហារ ដើម្បីឲ្យគេជួយឧបត្ថម្ភគាំទ្រ ដល់បេសកកម្មទាំងឡាយ តាមរយៈប្រូក្រាមសហការ និងការលើកដង្វាយពិសេសពីរដងក្នុងមួយឆ្នាំ។

---

អ្នករាល់គ្នានឹងធ្វើទីបន្ទាល់ពីខ្ញុំនៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងបំផុតនៃផែនដីផង។ (កិច្ចការ ១:៨)

---

## ហេតុផលដែលនាំឲ្យពួកគ្រីស្ទបរិស័ទ សោថឹនបាប់ទីស្ទ ធ្វើអ្វីដែលពួកគេធ្វើ

ចម្លើយទៅនឹងហេតុផលដែលនាំយើងឲ្យធ្វើអ្វីដែលយើងធ្វើ គឺងាយស្រួលបំផុត - គ្រីស្ទបរិស័ទសោថឹនបាប់ទីស្ទ ប្រកាសផ្សាយប្រាប់ដំណឹងល្អ ដល់មនុស្សម្នា គឺដោយសារសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ ដែលបានជំរុញពួកយើងឱ្យធ្វើដូច្នេះ (កូរិនថូស ទី២ ៥:១៤)។

ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់បញ្ជូនព្រះរាជបុត្រាទ្រង់តែ១ ដើម្បីមកបង់ថ្លៃទោសនៃអំពើបាបរបស់

យើង។ អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ បានជីវិតអស់កល្បជានិច្ច (យ៉ូហាន ៣:១៦)។ ជាចម្លើយឆ្លើយតបនឹងសេចក្តីស្រឡាញ់របស់ព្រះ ដែលទ្រង់ចាក់បង្ហូរមកលើយើងរាល់គ្នានេះ ព្រះអង្គបានហៅយើងរាល់គ្នា ឱ្យចេះសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក (យ៉ូហាន ១៣:៣៤-៣៥; ១៥:១២-១៧)។



ព្រះយេស៊ូវបានសង្ខេបសេចក្តីពិតនេះ ថាជាបញ្ញត្តិធំសំខាន់ជាងគេបំផុត (the Great Commandment) គឺត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឱ្យអស់អំពីចិត្ត អស់ពីព្រលឹង ហើយអស់អំពីគំនិត នេះជាបញ្ញតិយ៉ាងសំខាន់ទី១ ហើយបញ្ញត្តិទី២ក៏បែបដូចគ្នា គឺថាត្រូវឱ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង (ម៉ាថាយ ២២:៣៧-៣៩)។

គ្រីស្ទបរិស័ទសោចីនបាប់ទីស្ទស្គាល់**ផ្លូវ** នៃការអត់ទោសបាប និងការមានទំនាក់ទំនងល្អត្រឹមត្រូវជាមួយព្រះ; **ផ្លូវ**ដែលទទួលសេក្តីប្រោសលោះឲ្យរួចពីបាប រួចផុតពីផលវិបាករបស់វា; **ផ្លូវ**ដែលទទួលជីវិតអស់កល្ប - ជីវិតយូរអង្វែងអស់កល្បជានិច្ចនៅឋានសួគ៌ ជាជីវិតដែលពេញបរិបូរបំផុត -ជីវិតដែលស្គាល់*ព្រះអង្គ* (យ៉ូហាន១៧:៣) និង*ស្គាល់* ព្រះអង្គ (ភីលីព៣:១០)។ **ផ្លូវ**នោះ គឺ ព្រះយេស៊ូវ (យ៉ូហាន ១៤ :៦)។ សេចក្តីស្រឡាញ់ បង្ខំយើងឲ្យចែកចាយដំណឹងល្អ នៃសេចក្តីស្រឡាញ់របស់ព្រះអង្គចេញទៅ និងឈោងដៃទៅដើម្បីស្នើផ្តល់នូវការអត់ទោសរបស់ព្រះជាម្ចាស់ ដល់មនុស្សម្នា ឲ្យបានច្រើនបំផុត។

---

† គ្រប់កំណត់យោង(footnotes)ទាំងអស់ គឺជាសេចក្តីស្រង់ចេញមកពីឯកសារដើម នៃខិនវែនហ្សិន និងអាចរកបាននៅ "About" link នៅ SBC.net។ ដើម្បីទទួលព័ត៌មានបន្ថែម សូមទាក់ទងជាមួយ Convention Communications and Relations, SBC Executive Committee, លេខ 901 Commerce St., Nashville, TN 37 37203, 1-866-722-5433. ខែមិថុនា ឆ្នាំ២០១៦